**WWF-Cambodia**

21, Street 322,
Boeung Keng Kang I,
Phnom Penh, Cambodia
P.O. Box: 2467

Tel: +855 23 218 034
Fax: +855 23 211 909

www.wwf.org.kh
www.panda.org/greatermekong
wwfcambodia@wwf.org.kh

WWF for a living planet®

សេចក្តីប្រកាសសារព័ត៌មាន　　　　សម្រាប់ចេញផ្សាយបន្ទាន់

# សត្វរមាំងដែលជាប្រភេទសត្វរងគ្រោះថ្នាក់ជិតផុតពូជត្រូវបានអ្នកវិទ្យាសាស្ត្រស្រាវជ្រាវរកឃើញក្នុងតំបន់ទេសភាពមេគង្គជាលើកដំបូងក្នុងអំឡុងពេលប្រាំឆ្នាំ

**ដែនជម្រកសត្វព្រៃសំបូរ ខេត្តក្រចេះ៖** អ្នកវិទ្យាសាស្ត្របានបង្ហាញរូបភាពសត្វរមាំង (*Rucervus eldii)* ចំនួនបួនក្បាលដែលគេថតបានជាលើកដំបូងក្នុងអំឡុងពេលប្រាំឆ្នាំ តាមរយៈការប្រើម៉ាស៊ីនថតស្វ័យប្រវិត្ត នៅក្នុងដែនជម្រកសត្វព្រៃសំបូរ ដែលជាតំបន់ការពារធម្មជាតិមួយស្ថិតក្រោមការគាំទ្រដោយអង្គការ WWF មានទីតាំងស្ថិតក្នុងតំបន់ទេសភាពព្រៃលិចទឹកមេគង្គនៃខេត្តក្រចេះ។ សត្វរមាំងត្រូវបានចាត់ថ្នាក់ជាប្រភេទសត្វរងគ្រោះថ្នាក់ជិតផុតពូជ ទាំងនៅក្នុងច្បាប់ព្រៃឈើរបស់ប្រទេសកម្ពុជា និងក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ។

ក្រុមអ្នកអភិរក្សបានបង្ហាញក្តីរំភើបរីករាយ ខណៈពួកគេកំពុងពិនិត្យមើលរូបភាពដ៏កម្រនៃវត្តមានរបស់សត្វរមាំងញីពេញវ័យចំនួនបីក្បាល និងរមាំងជំទង់មួយក្បាល កំពុងរស់នៅក្នុងដែនជម្រកសត្វព្រៃសំបូរ ក្នុងចំណោមរូបថតសរុបចំនួន ១.៧១០ សន្លឹក ថតបានក្នុងចន្លោះខែសីហាដល់ខែកញ្ញានេះ ដោយការពង្រាយម៉ាស៊ីនថតរូបស្វ័យប្រវិត្តនៅតាមទីតាំងផ្សេងៗគ្នាក្នុងដែនជម្រក ដែលមានផ្ទៃដីសរុបចំនួន ៥០.០៩៣ ហិកតា។ **លោក អៀម សំអ៊ន់ អ្នកទទួលបន្ទុកផ្នែកស្រាវជ្រាវនិងតាមដានជីវៈចម្រុះប្រចាំតំបន់មេគង្គនៃអង្គការ**WWF បានថ្លែងដោយស្នាមញញឹមថា៖ "យើងទាំងអស់គ្នាពិតជារំភើបរីករាយខ្លាំងណាស់ដែលបានកត់ត្រាទុកនូវវត្តមានរបស់សត្វរមាំងទាំងនេះ។"

ការស្រាវជ្រាវនិងតាមដានសត្វព្រៃដោយម៉ាស៊ីនថតស្វ័យប្រវត្តិក្នុងដែនជម្រកសត្វព្រៃនេះជាកិច្ចសហការរួមគ្នាដោយក្រុមអ្នកស្រាវជ្រាវនិងឧទ្យានុរក្សនៃមន្ទីរបរិស្ថានខេត្តក្រចេះ សហគមន៍ព្រៃឈើ បុគ្គលិកអង្គការWWF និងសមាជិកក្រុមល្បាតសហគមន៍ ក្រោមការឧបត្ថម្ភថវិកាដោយអង្គការ WWF-ប៊ែលហ្សិក និងទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការ (SDC)។ អ្នកវិទ្យាសាស្ត្រនៃអង្គការWWF បានពិពណ៌នាការផ្តិតរូបភាពរបស់សត្វរមាំងបានម៉ាស៊ីនថតស្វ័យប្រវត្តិនេះថាជារបកគំហើញដ៏សំខាន់មួយសម្រាប់ការអភិរក្សក្នុងតំបន់ទេសភាពមេគង្គ។

**លោក សេង ទៀក នាយកអង្គការ** WWF-**កម្ពុជា** បានមានប្រសាសន៍ថា៖ "រូបភាពដ៏កម្រនៃសត្វរមាំងទាំងនេះជាភស្តុតាងបញ្ជាក់អំពីប្រសិទ្ធភាព និងផលនៃកិច្ចការគ្រប់គ្រងតំបន់ការពារ និងការងារអភិរក្សរបស់យើង ហើយដែលនាំមកនូវក្តីសង្ឃឹមក្នុងការការពារប្រភេទសត្វនេះទាំងក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។"

ក្រៅពីសត្វរមាំង ម៉ាស៊ីនថតស្វ័យប្រវិត្តក៏ផ្តិតបាននូវរូបភាពសត្វឈ្លូស ជ្រូកព្រៃ សំពោចវល្លិ៍ សំពោចក្រអូប ព្រមទាំងប្រភេទសត្វបក្សីមាឌធំសំខាន់ៗមួយចំនួនទៀត ដូចជាសត្វក្ងោកបៃតង និងត្រដក់តូចជាដើម។

របាយការណ៍ស្តីពីប្រភេទសត្វទទួលរងការគំរាមកំហែងដែលបានចេញផ្សាយដោយអង្គការ IUCN ក្នុងឆ្នាំ២០១៥ បានបង្ហាញថាចំនួនសត្វរមាំងមាននៅរាយប៉ាយក្នុងសកលលោក ហើយគេបាន ប៉ាន់ប្រមាណថា សត្វនេះមានចំនួនតិចជាង ៧០០ ក្បាល  ហើយក្នុងនោះ ចំនួនសត្វរមាំងមាននៅសេសសល់តិចតួចប៉ុណ្ណោះ កំពុងរស់នៅក្នុងតំបន់ព្រៃ

ការពារនានាក្នុងប្រទេសកម្ពុជា។ អង្គការ WWF បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជាគ្រប់ជាន់ថ្នាក់ដើម្បីគាំទ្រការគ្រប់គ្រងដែនជម្រកសត្វព្រៃសំបូរ ដែលនៅទីនោះ ការបាត់បង់ទីជម្រក និងការបរបាញ់សត្វព្រៃសម្រាប់យកសាច់ និងសម្រាប់ការជួញដូរសុទ្ធសឹងជាកត្តាគំរាមកំហែងចំបងៗ ទៅលើធនធានធម្មជាតិ និងការរស់រានរបស់សត្វព្រៃ។

ក្នុងឆមាសទីមួយឆ្នាំនេះ កិច្ចសហការរួមគ្នាក្នុងការពង្រឹងការអនុវត្តច្បាប់របស់មន្ត្រីឧទ្យានុរក្សនៃមន្ទីរបរិស្ថានខេត្ត សមាជិកសហគមន៍ល្បាតដែលជាអ្នករស់នៅជុំវិញនិងក្បែរដែនជម្រកសត្វព្រៃ អាជ្ញាធរមូលដ្ឋាន និងបុគ្គលិកអង្គការ WWF បានបញ្ឈប់ករណីទន្ទ្រានដីព្រៃខុសច្បាប់ចំនួន ៣៣ ករណី ដែលគិតជាផ្ទៃដីសរុបចំនួន ៥៩៤ ហិកតា ដោយបានដកបង្គោលឈើព្រំខុសច្បាប់ចំនួន ១០២ ដើម បានដកហូតត្រាក់ទ័រចំនួន ៥ គ្រឿង និងអិចស្កាវ៉ាទ័រចំនួនមួយគ្រឿង។ ក្នុងប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ទាំងនោះដែរ ក្រុមការងារក៏បានបង្ក្រាបករណីកាប់ឈើខុសច្បាប់ចំនួន ៣៦ ករណី ដោយដកហូតឈើប្រណិតចំនួន ២៣ ដុំ និងរណាយន្តចំនួន ១១ គ្រឿង។ ស្របពេលជាមួយគ្នានោះដែរ ក្រុមការងារក៏បានដោះនិងប្រមូលអន្ទាក់ចេញពីដែនជម្រកសត្វព្រៃសំបូរ បានចំនួន ២៧៨ អន្ទាក់ ព្រមទាំងបានដោះអន្ទាក់អគ្គិសនីបានចំនួនប្រាំឈុតផងដែរ។

**លោក សេខ ទៀក** បានថ្លែងសរសើរថា៖ "យើងខ្ញុំសូមកោតសរសើរចំពោះក្រុមការងារពង្រឹងការអនុវត្តច្បាប់ទាំងអស់ដែលបានបំពេញតួនាទីដ៏សំខាន់នេះក្នុងការដើរល្បាតជាប្រចាំក្នុងដែនជម្រកសត្វព្រៃ និងពង្រឹងការអនុវត្តច្បាប់ស្តីពីតំបន់ការពារ និងច្បាប់ព្រៃឈើ។" លោកបានមានប្រសាសន៍បន្ថែមទៀតថា៖ "កិច្ចខិតខំប្រឹងប្រែងទាំងនេះជាកត្តាចំបងមួយធ្វើឲ្យជនខិលខូចមានការខ្លាចរអា និងអាចទប់ស្កាត់បទល្មើសសត្វព្រៃនិងព្រៃឈើ ដើម្បីអនុញ្ញាតឱ្យសត្វព្រៃរួចផុតពីភាពភ័យខ្លាច និងអាចរស់នៅដោយសេរីភាពក្នុងដែនជម្រកសត្វព្រៃដែលមានសុវត្ថិភាព"។

ការស្រាវជ្រាវជីវៈចម្រុះ និងការពង្រឹងការអនុវត្តច្បាប់សុទ្ធសឹងជាធាតុសំខាន់ៗសម្រាប់តំបន់ការពារធម្មជាតិនៅក្នុងតំបន់ទេសភាពមេគង្គ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អង្គការ WWF-កម្ពុជា បាននិងកំពុងស្រាវជ្រាវ និងតាមដានសត្វព្រៃទាំងប្រភេទរស់នៅលើគោក និងប្រភេទរស់នៅក្នុងទឹក អស់រយៈកាលជាងពីរទសវត្សរ៍មកហើយ ខណៈដែលបាននិងកំពុងផ្តល់ការគាំទ្រយ៉ាងសកម្មដល់ការអនុវត្តនិងការពង្រឹងការអនុវត្តច្បាប់ព្រៃឈើនិងជលផល ក៏ដូចជាការអនុវត្តន៍កម្មវិធីផ្សេងៗទៀតដើម្បីលើកទឹកចិត្ត និងកៀរគរការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍជីវភាពរបស់សហគមន៍ដើម្បីលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន។

*************************

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក ទេព អស្នារិទ្ធ ប្រធានកិច្ចការសាធារណៈ និងគ្រប់គ្រងព័ត៌មាននៃអង្គការ WWF-កម្ពុជា
អ៊ីម៉េល៖ asnarith.tep@wwf.org.kh ទូរស័ព្ទ៖ ០១២ ៩៥៧ ៩១៩

**ព័ត៌មានសម្រាប់អ្នកនិពន្ធ៖**

សូមទាញយករូបភាពតាមរយៈតំណរនេះ៖ https://rb.gy/vvi7tu

**អំពីការស្រាវជ្រាវ និងតាមដានសត្វព្រៃដោយប្រើម៉ាស៊ីនថតស្វ័យប្រវត្តិ**

ការស្រាវជ្រាវ និងតាមដានសត្វព្រៃដោយប្រើម៉ាស៊ីនថតស្វ័យប្រវត្តិជាផ្នែកដ៏សំខាន់មួយនៃកម្មវិធីស្រាវជ្រាវសត្វព្រៃរបស់យើងសម្រាប់ចងក្រងឯកសារស្តីពីធនធានជីវៈចម្រុះនៅក្នុងតំបន់គោលទាំងអស់ ដើម្បីបង្កើនចំណេះដឹងអំពី

របាយសត្វព្រៃ ប្រភេទទីជម្រក ដែលសុទ្ធសឹងជាពត៌មានចាំបាច់សម្រាប់រួមចំណែកដល់ការប៉ាន់ប្រមាណនូវចំនួនសត្វព្រៃដែលរស់នៅក្នុងតំបន់គោលដៅទាំងនោះ។

**អំពីដែនជម្រកសត្វព្រៃសំបូរ**

ក្នុងខែតុលា ឆ្នាំ២០១៨ ដែនជម្រកសត្វព្រៃសំបូរ ស្ថិតក្នុងស្រុកសំបូរខេត្តក្រចេះ និងតំបន់ការពារធម្មជាតិមួយទៀតមានឈ្មោះថា ដែនជម្រកសត្វព្រៃប្រសព្វ ត្រូវបានប្រកាសជាផ្លូវការ ជា "តំបន់ការពារដែនជម្រកសត្វព្រៃ" ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។ ដែនជម្រកសត្វព្រៃទាំងពីរនេះទ្រទ្រង់ប្រភេទទីជម្រកព្រៃធម្មជាតិ និងប្រព័ន្ធទឹកទន្លេសំខាន់ៗដែលមិនទាន់រងការប៉ះពាល់ ខណៈដែលដង់ស៊ីតេប្រជាជននៅទីនោះស្ថិតក្នុងកម្រិតទាប។ យោងតាមការស្រាវជ្រាវជីវៈចម្រុះឆ្នាំ២០០៦-២០០៧ អ្នកវិទ្យាសាស្ត្របានកត់ត្រាទុកនូវ ពពួកថនិកសត្វមានធំចំនួន ១១ ប្រភេទ ពពួកឧរង្គសត្វ និងល្មូន ចំនួន ៥៦ ប្រភេទ ពពួករុក្ខជាតិចំនួន ៦៨៣ ប្រភេទ ពពួកបក្សីចំនួន ២១៥ ប្រភេទ និងពពួកត្រី ចំនួន ២២៣ ប្រភេទ។ ប្រព័ន្ធទន្លេនិងព្រៃឈើនៅក្នុងតំបន់នេះ ជាប្រភពចំណីអាហារ និងសម្រាប់បង្កើតឱកាសទាញយកប្រាក់ចំណូលដ៏សំខាន់សម្រាប់សហគមន៍មូលដ្ឋាន។ បន្ថែមលើនេះទៀត ប្រព័ន្ធអេកូឡូស៊ីធម្មជាតិក៏ជួយដល់មនុស្សជាតិក្នុងការប្រឈមនឹងបម្រែបម្រួលអាកាសធាតុ ទឹកជំនន់ និងគ្រោះរាំងស្ងួតផងដែរ។

**អំពីWWF**

អង្គការមូលនិធិសកលសម្រាប់ធម្មជាតិ (WWF) ជាអង្គការអភិរក្សធម្មជាតិឯករាជ្យមួយ ដែលមានអ្នកគាំទ្រជាង ៣០ លាននាក់ និងមានបណ្តាញបេសកកម្មនៅក្នុង១០០ប្រទេសលើពិភពលោក។ បេសកកម្មរបស់យើងគឺបញ្ឈប់ការរេចរឹលនៃបរិស្ថានធម្មជាតិរបស់ភពផែនដី និងដើម្បីកសាងអនាគតមួយដែលមនុស្សរស់នៅដោយសុខដុមជាមួយនឹងធម្មជាតិ តាមរយៈការអភិរក្សជីវៈចម្រុះរបស់ពិភពលោក ធានាការប្រើប្រាស់ដោយចីរភាពនូវធនធានកកើតឡើងវិញ និងលើកកម្ពស់ការកាត់បន្ថយការបំពុលនិងការប្រើប្រាស់ខ្ជះខ្ជាយ។

សូមចូលចូលទៅកាន់ទំព័រ Facebook និង Twitter របស់យើងដើម្បីទទួលបាននូវដំណឹងថ្មីៗ និងសូមចូលទៅកាន់គេហទំព័ររបស់យើងគឺ www.wwf.org.kh ដើម្បីទទួលបានព័ត៌មានផ្សេងៗទៀត។